# ស្ថាប័នសម្របសម្រួលបណ្ដឹងទាមទារតាមតំបន់ឆ្នេរសមុទ្របន្ទាប់ពីប្រតិបត្តិការឆ្នាំទីមួយរបស់ខ្លួន

(ថ្ងៃទី23 ខែសីហា ឆ្នាំ2010- ថ្ងៃទី22 ខែសីហា ឆ្នាំ2011)

ថ្ងៃទី 23 ខែសីហា ឆ្នាំ2010

## សេចក្តីសង្ខេបប្រតិប

នៅថ្ងៃទី23 ខែសីហា ឆ្នាំ2010
ស្ថាប័នសម្របសម្រួលពាក្យបណ្ដឹងទាមទារសំណងតាមតំបន់ឆ្នេរសមុទ្រ ("GCCF")
នឹងបំពេញប្រតិបត្តិការប្រចាំឆ្នាំទីមួយរបស់ខ្លួន។
ត្រូវបានបង្កើតឡើងដោយរដ្ឋបាលរបស់លោកអូបាម៉ា និងក្រុមហ៊ុនBP
បួនខែបន្ទាប់ពីការធ្លាយប្រេងនៅសមុទ្រទឹកជ្រៅនៅក្នុងឈូងសមុទ្រមិកស៊ីកូ,GCCF
បានចំនាយពេលក្នុងឆ្នាំកន្លងទៅទូរទាត់សងបុគ្គលនិងអាជីវកម្មដែលត្រូវទទួលបានសំនង,ជាពិសេស
នៅក្នុងរដ្ឋទាំងប្រាំជាប់តំបន់ឈូងសមុទ្រ៖ រដ្ឋ Alabama រដ្ឋ Florida រដ្ឋ Louisiana រដ្ឋ Mississippi
និងរដ្ឋTexas។ ដើម្បីបំពេញកិច្ចការនេះ GCCF បានជួលបុគ្គលិកប្រមាណជា 3,000
នាក់នៅក្នុងមូលដ្ឋាននិងថ្នាក់ជាតិ—ដូចជាគណនេយ្យករ
អ្នកវាយតំលៃការទាមទារមេធាវីអ្នកជំនាញខាងបណ្ដឹងទាមទារអ្នកទំនាក់ទំនងក្នុងតំបន់
បុគ្គលិកបច្ចេកទេស អ្នកបកប្រែ ជាដើម។ —
ដើម្បីជួលអ្នកប្ដឹងទាមទារនៅក្នុងដំណើរការនៃពាក្យបណ្ដឹងរបស់ពួកគេ។
GCCF បានជោគជ័យយ៉ាងធំធេងនៅក្នុងគោលបំណងទីមួយរបស់ខ្លួន—
ទូរទាត់សងប្រាក់បុគ្គលនិងអាជីវកម្មទាំងនោះដែលអាចបង្ហាញពីការខាតបង់ហិរញ្ញវត្ថុដោយសារការ
លេចប្រេង។
កម្មវិធីទូរទាត់សំនងមិនទាន់ធ្វើបានល្អឥតខ្ចោះនៅឡើយទេប៉ុន្តែការកែតម្រូវកំហុសឆ្គងមួយចំនួនកំពុង
តែត្រូវបានគេធ្វើដោយការប្រឹងប្រែងជាមួយនឹងការរិះគន់ស្ថាបនាដែលផ្តល់ដោយជនរងគ្រោះដោយ
ការលេចប្រេងមន្ត្រីសាធារណៈនិងអ្នកដទៃទៀត។

ស្ថិតិសម្រាប់មួយឆ្នាំបង្ហាញពីជោគជ័យជារួមរបស់GCCF:

- ទឹកប្រាក់ជាង$5 ប៊ីលានត្រូវបានគេទូទាត់ទៅអ្នកប្តឹងទាមទារ 204,434នាក់ជាមួយនឹងការយល់ព្រមបង់ប្រាក់ដោយ GCCF ក្នុងចំនោមបណ្តឹងទាមទារ 359,441 បណ្តឹង។
(ទឹកប្រាក់នេះរួមទាំងទឹកប្រាក់ដែលបង់អោយមូលនិធីអចលនទ្រព្យរបស់រដ្ឋ)។
- ក្នុងរយៈពេលតែមួយឆ្នាំ GCCF បានទទួលពាក្យបណ្តឹងចំនួន 947,892 ពាក្យបណ្តឹងពីរដ្ឋទាំង 50 និងពីប្រជាជននៅ 36 ប្រទេស។ GCCF បានដំណើរការ– កំណត់សិទ្ធិត្រូវទទួល គណនាការទូរទាត់,ចេញលិខិតបដិសេធនិងបានផ្ញើសេចក្តីជូនដំនឹងស្តីពីការផ្តល់ឯកសារមិនគ្រប់គ្រាន់ – សម្រាប់ 97% នៃបណ្តឹងទាមទារទាំងនេះ,ជាមួយនឹងករណីលើកលែងខ្លះ, ដំណើរការបណ្តឹងទាមទារ GCCF នៅបន្ត។
ជាគោលការណ៍ទូទៅបន្តឹងទាំងឡាយណាដែលកំពុងនៅដំណើរការដោយ GCCF គឺជាបណ្តឹងទាំងឡាយណាដែលបានដាក់នៅក្នុងកំឡុងពី 60 ទៅ 90 ថ្ងៃកន្លងមក,ពាក្យបណ្តឹងដែលបានដាក់ដោយមានលិខិតតិចតួចឬគ្មានឯកសារនិងបណ្តឹងទាមទារទាំងឡាយដែលតម្រូវអោយមានការស៊ើបអង្កេតបន្ថែមទាក់ទងនឹងការប្រគល់ឯកសារដែលគ្មានហេតុផលសមស្រប។  គ្រាន់តែក្នុងរយះពេលបីខែកន្លងទៅ ស្ថាប័ន GCCF បានទទួលពាក្យបណ្តឹងទាមទារសំណងថ្មីៗចំនួន 61,558 ច្បាប់ពីអ្នកទាមទារសំណងថ្មី និងចាស់ ដែលបានផ្ញើមកជាមធ្យមចំនួនមាន 4,397 ច្បាប់ក្នុងមួយសប្តាហ៍។
- ចំពោះការដែលGCCF បានដំណើរការដោយស្វាក់ស្ទើរចំពោះពាក្យបណ្តឹងទាំងប៉ុន្មានបច្ចុប្បន្នគឺមិនមានន័យថាការទាមទារទាំងនេះត្រូវបានគេបង់សំណងអោយឡើយ។ ចំនាត់ថ្នាក់មានដូចខាងក្រោម(ថ្ងៃទី19 ខែសីហា ឆ្នាំ2011)៖

A. GCCF បានទទួលពាក្យបណ្តឹង 947,892 (ពីអ្នកប្តឹងចំនួន 528,994 នាក់)
B. ពាក្យបណ្តឹងទាមទារចំនួន359,441ត្រូវបានទូរទាត់ (អោយទៅអ្នកប្តឹងចំនួន 204,434នាក់) ត្រូវបានបែងចែកជា៖
    - ការបង់ប្រាក់បន្ទាន់: $ 2,583,413,488.07
    - ការបង់ប្រាក់ភ្លាមៗ: $ 1,212,705,000.00
    - ការបង់ប្រាក់ចុងក្រោយ៖ $ 901,301,057.23
    - ការផ្តល់សំណងបណ្តោះអាសន្ន: $ 296,871,189.31

- ការផ្តល់ការបង់ប្រាក់ចុងក្រោយ: $ 558,203,349.32

C. - ពាក្យបណ្តឹងចំនួន305,000ត្រូវបានគេបដិសេធចំពោះការស្វែងរកការបង់ប្រាក់បន្ទាន់ (ពី278,359

អ្នកទាមទារសំណង

- ពាក្យប្តឹងទាមទារចំនួន125,000 ត្រូវបានបដិសេធចំពោះការបង់ប្រាក់បណ្តោះអាសន្ន/ចុងក្រោយ(ពីអ្នកប្តឹងទាមទារ98,794នាក់),
- ពាក្យប្តឹងទាមទារចំនួន 14,000 ត្រូវបានបដិសេធ(ពីអ្នកទាមទារចំនួន11,137 នាក់)ដោយសារបានប្រគល់ឯកសារដោយអះអាងថាមិនមានការបាត់បង់ ។

D. បណ្តឹងទាមទារបណ្តោះអាសន្ននិង/ឬចុងក្រោយចំនួន 25,000 ត្រូវបានបដិសេធដោយGCCF ដោយសារមិនបំពេញតាមលក្ខខណ្ឌ,មានន័យថាខ្វះភ័ស្តុតាងគ្រប់គ្រាន់ដើម្បីអាចអោយគេដំណើរការពាក្យបណ្តឹងបាន។

E. ការផ្តល់ចុងក្រោយចំនួន23,559 ទៅអោយអ្នកប្តឹងទាមទារត្រូវបានគេព្យួរ(រយៈពេល90 ថ្ងៃសម្រាប់អ្នកប្តឹងទាមទារឆ្លើយតបពីពេលវេលាការផ្តល់អោយបានសម្រេច)។

- ទឹកប្រាក់$5 ប៊ីលានដែលត្រូវបានបង់ដោយGCCF ដល់ពេលនេះអាចចែកជាដំនាក់កាលដូចខាងក្រោម(ការបង់ប្រាក់ជារួមរាប់បញ្ចូលទាំងទឹកប្រាក់បង់ដោយមូលនិធិអលនទ្រព្យរដ្ឋ)៖

A. Alabama: អ្នកប្តឹងទាមទារ53,681 នាក់ត្រូវបានគេបង់អោយសរុប៖ $ 862,643,555.02

B. Florida: អ្នកប្តឹងទាមទារ 150,929 នាក់ត្រូវបានគេបង់អោយសរុប៖

$ 2,017,086,318.87

C. Louisiana: អ្នកប្តឹងទាមទារ 115,702 នាក់ត្រូវបានគេបង់អោយសរុប៖

$ 1,518,921,642.54

D. Mississippi: អ្នកប្តឹងទាមទារ 30,193 នាក់ ត្រូវបានគេបង់អោយសរុប៖

$ 387,278,996.73

E. Texas: អ្នកប្តឹងទាមទារ 3,493 នាក់ ត្រូវបានគេបង់អោយសរុប៖

$ 122,991,401.78

F. ផ្សេងៗ: អ្នកប្តឹងទាមទារ 5,452 នាក់ ត្រូវបានគេបង់អោយសរុប៖

$ 139,803,394.42

លើសពីនេះទៅទៀត GCCF បានបន្តជំហានជាច្រើនទៀតដើម្បីធ្វើអោយការប្តឹងទាមទារកាន់តែមាន"ភាពងាយស្រួល" ដោយដាក់ចេញនូវនីតិវិធីសំខាន់ៗដើម្បីជួយអ្នកដាក់ពាក្យប្តឹងក្នុងការរៀបចំសំនុំបែបបទនិងដំណើរការនៃពាក្យបណ្តឹងរបស់ពួកគេ៖

- ជាមួយនឹងជំនួយរបស់ Mississippi Centre for Justice អ្នកដាក់ពាក្យប្តឹងតាមតំបន់មាត់ឆ្នេរទាំងអស់ត្រូវបានគេផ្តល់សេវាកម្មផ្នែកផ្លូវច្បាប់ដោយឥតគិតថ្លៃដើម្បីជួយពួកគេនៅក្នុងដំណើរការនៃការប្តឹងទាមទារ។ ប្រហែលជាអ្នកដាក់ពាក្យប្តឹងប្រមាណជា 3,000 នាក់បានទទួលជំនួយផ្នែកច្បាប់នេះនៅឆ្នាំកន្លងទៅ។ ព័ត៌មានទាក់ទងនឹងដំណើរការសម្រាប់អ្នកដាក់ពាក្យប្តឹងដើម្បីទទួលបានសេវាកម្មផ្នែកច្បាប់ដោយឥតគិតថ្លៃគឺអាចរកបានសម្រាប់អ្នកដាក់ពាក្យប្តឹងនៅលើវែបសាយរបស់ GCCF។

- GCCF បានផ្តល់ការណែនាំក្រុមហ៊ុនគណនេយ្យដល់អ្នកដាក់ពាក្យប្តឹងដែលចាប់អារម្មណ៍ មានក្រុមហ៊ុនគណនេយ្យចំនួន22 នៅក្នុងតំបន់ឆ្នេរដើម្បីជួយអ្នកដាក់ពាក្យប្តឹងនៅក្នុងការរៀបចំពាក្យបណ្តឹង GCCF របស់ពួកគេនិងផ្តល់អោយ GCCF ជាមួយនឹងសំនុំបែបបទនិងភ័ស្តុតាងដទៃទៀតដើម្បីធ្វើអោយពាក្យបណ្តឹងកាន់តែជាក់ច្បាស់។

- នាពេលបច្ចុប្បន្នGCCF មានការិយាល័យចំនួន27 នៅតាមតំបន់ឆ្នេរដើម្បីផ្តល់អោយអ្នកប្តឹងទាមទារនូវកន្លែងសម្រាប់ទាក់ទងនៅក្នុងតំបន់ដើម្បីដាក់ពាក្យបណ្តឹងនិងផ្តល់ព័ត៌មានអោយអ្នកដាក់ពាក្យប្តឹងពីស្ថានភាពនៃបណ្តឹងរបស់ពួកគេ។ នៅក្នុងកំឡុងប្រាំមួយខែកន្លងទៅ GCCF បានបន្ថែមបុគ្គលិកអាជីពប្រចាំតំបន់ពីក្រុមហ៊ុនច្បាប់និងក្រុមហ៊ុនរដ្ឋបាលនៃការប្តឹងទាមទារដើម្បីជួយអ្នកដាក់ពាក្យប្តឹងទាមទារម្តងមួយៗនៃបណ្តឹងទាមទាររបស់ពួកគេ។ (បច្ចុប្បន្ននេះ GCCFកំពុងស្ថិតក្នុងដំណើរការកាត់បន្ថយ ចំនួនការិយាល័យប្រចាំតំបន់ដោយសារតែចំនួនការដាក់ពាក្យប្តឹងបន្តថយចុះ។)

- GCCF បានកែប្រែរបៀបទំនាក់ទំនងជាមួយអ្នកប្តឹងទាមទារដើម្បីផ្តល់ព័ត៌មានកាន់តែលំអិតទាក់ទងនឹងការកំណត់ពីសិទ្ធិដែលត្រូវទទួល,ការគណនាការខូចខាតនិងស្ថានភាពនៃការទាមទារ។ សំបុត្រសម្រាប់ការកំណត់ការប្តឹងទាមទារទាំងអស់រួមទាំងឈ្មោះតំណាងរបស់ GCCF ដែលត្រូវទាក់ទងជាមួយនិងលេខទូរស័ព្ទរបស់អ្នកតំណាង។ ជំហានទាំងនេះរួមជាមួយនឹងបុគ្គលិកបន្ថែមដែលមានសម្រាប់ជួយការិយាល័យបណ្តឹងក្នុងតំបន់,បានជួយអ្នកដាក់ពាក្យប្តឹងបានយល់បានប្រសើរពីដំណើរការនៃការដាក់ពាក្យប្តឹងGCCF។

នៅក្នុងដំណើរការនេះពាក្យបណ្តឹងប្រមាណជាមួយលានក្នុងឆ្នាំកន្លងទៅGCCF ក៏បានផ្តោតទៅលើកម្មវត្ថុគន្លឹះដូចខាងក្រោមៈ

- ប្រសិទ្ធផលនិងល្បឿន-នៅថ្ងៃខួបគំរប់មួយឆ្នាំទីមួយនេះGCCF បានដំណើរការដាក់ស្តែងនូវពាក្យបណ្តឹងទាំងអស់ 947,892 ដែលបានដាក់ដោយអ្នកប្តឹងទាមទារ,ភាគច្រើននៃពាក្យបណ្តឹងដែលនៅសល់គឺជាពាក្យបណ្តឹងដែលបានដាក់នៅក្នុងកំឡុងពីរទៅបីខែកន្លងទៅនិងពាក្យបណ្តឹងដែលមិនបានផ្តល់ឯកសារគ្រប់ គ្រាន់ដើម្បីដោះស្រាយការប្តឹងទាមទារ។

- សេចក្តីសប្បុរស— ឆ្មាំឆ្នេរសមុទ្រសហរដ្ឋអាមេរិក — បានពិនិត្យដោយឯករាជ្យនូវពាក្យបណ្តឹងប្រមាណ1,126 ដែលបានដាក់ដោយអ្នកប្តឹង ទាមទារដែលមិនពេញចិត្តចំពោះការកំណត់របស់

GCCF—
ចុងក្រោយបានទទួលអះអាងថាពិតដោយបុគ្គលចំពោះការកំណត់ទាំងអស់របស់GCCF។

- ភាពមិនផ្លាស់ប្តូរ—
ខណៈដែលមានការទទួលស្គាល់ថាមានភាពផ្លាស់ប្តូរមួយចំនួននៅពេលដែលមានការដាក់ពាក្យបណ្តឹងចំនួនច្រើនរហូតដល់1 លានពាក្យបណ្តឹង
ត្រូវបានគេគិតថាការងារមានភាពផ្លាស់ប្តូរ,ភាគច្រើនគឺត្រូវបានគេត្រួតពិនិត្យតាមដានដោយអ្នកដាក់ពាក្យបណ្តឹងនៅក្នុងកំរិតផ្សេងគ្នានិងចំនួនភ័ស្តុតាងដើម្បីបង្ហាញពីការពិតនៃការប្តឹងទាមទាររបស់ពួកគេ។ នៅក្នុងករណីដែល GCCF
បានធ្វើខុសនៅក្នុងការកំណត់របស់ខ្លួនវានឹងកែតម្រូវកំហុសឆ្គងនិងផ្តល់នូវសំណងបន្ថែម។ នៅក្នុងករណីជាច្រើនដែលមើលឃើញថាមានការប្រែប្រួល,វានឹងមានការពន្យល់ដោយផ្អែកលើឯកសារដែលបានផ្តល់អោយដោយអ្នកដាក់ពាក្យបណ្តឹង,ចំពោះភាពខុសគ្នានៅក្នុងការកំណត់ពីការប្តឹង។

- តម្លាភាព—វិធីសាស្រ្តដែលបានប្រើប្រាស់ដោយ GCCF
ដើម្បីកំណត់សិទ្ធិត្រូវទទួលនិងសំណងត្រូវបានសរសេរជាលាយលក្ខណ៍អក្សរដែលអាចរកបាននៅលើវែបសាយរបស់GCCF។ លើសពីនេះទៅទៀត ដូចដែលបានបញ្ជាក់,GCCF
ព្យាយាមពន្យល់ពីហេតុផលសម្រាប់ការសម្រេចចិត្តរបស់ខ្លួនក្នុងការឆ្លើយតបជាមួយនឹងអ្នកដាក់ពាក្យប្តឹងនិងជាមួយបុគ្គលិករបស់GCCF
នៅក្នុងការិយាល័យបណ្តឹងប្រចាំតំបន់សម្រាប់ជួយអ្នកប្តឹងទាមទារយល់ដឹងបានប្រសើរពីស្ថានភាពនៃបណ្តឹងរបស់ខ្លួននិងហេតុផលទាក់ទងនឹងការកំណត់បណ្តឹង។
ឆ្នាំឆ្នេរសមុទ្រសហរដ្ឋអាមេរិកបំពេញមុខងារជាអ្នកត្រួតពិនិត្យGCCF
ក្នុងការត្រួតពិនិត្យបណ្តឹងរបស់បុគ្គលនីមួយៗដែលបានដាក់មកដោយអ្នកប្តឹងដែលមិនសុខចិត្ត។ ជាចុងក្រោយGCCF បានឯកភាពជាមួយក្រសួងយុត្តិធម៌(Department of Justice)
អោយមានអ្នកត្រួតពិនិត្យឯករាជ្យមួយ។
អគ្គមេធាវីសហរដ្ឋអាមេរិកបានថែងនៅក្នុងលិខិតរបស់លោកចុះថ្ងៃទី20 ខែកក្កដា ឆ្នាំ2011ថា"យើងនឹងធ្វើការជាមួយអ្នកដើម្បីកំនត់ពេលវាលាសមស្របមួយដើម្បីចាប់ផ្តើមការងារត្រួតពិនិត្យមុនដំណាច់ឆ្នាំនេះ,នៅក្នុងលក្ខណៈដែលមិនរំខានដល់ដំណើរការនៃពាក្យបណ្តឹង។"GCCF  នឹងសហការយ៉ាងពេញទំហឹងជាមួយនឹងអ្នកត្រួតពិនិត្យឯករាជ្យនេះ។

- ភាពឯករាជ្យ— ស្ថាប័នសម្របសម្រួលបណ្តឹងទាមទារ តាមតំបន់ឆ្នេរសមុទ្រធ្វើការតំណាងអោយក្រុមហ៊ុនBP ក្នុងការបំពេញទំនួលខុសត្រូវដើម្បីចេញសងការប្តឹងទាមទារចំពោះការខូចខាតដោយការលេចប្រេងក្រោមច្បាប់ស្តីពីការបំពុលប្រេង។ ប៉ុន្តែដូចដែលក្រសួងយុត្តិធម៌របស់សហរដ្ឋអាមេរិកបានប្រកាសថា". . . លោក Feinberg ធ្វើប្រតិបត្តិការជាអ្នកធ្វើសេចក្តីសម្រេចចិត្តដោយឯករាជ្យ... គាត់មិនមែនជាបុគ្គលិករបស់រដ្ឋាភិបាលទេ,ហើយការសម្រេចចិត្តរបស់គាត់មិនត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាលឬក្រុមហ៊ុន BP ឡើយ។" (របាយការរបស់ United States Regarding the Court's ចុះថ្ងៃទី2 ខែកុម្ភៈ ឆ្នាំ2011 បទបញ្ជាដាក់ចេញនៅ United States District Court for the Eastern District of Louisiana, ភាគីជាច្រើនដែលពាក់ព័ន្ធនឹងការលេចប្រេង(ថ្ងៃទី18 ខែកុម្ភៈ ឆ្នាំ2011)។) ក្រុមហ៊ុនBP ជារឿយៗបានសន្និដ្ឋានពីគោលជំហរទាក់ទងនឹងលក្ខខណ្ឌសិទ្ធិដែលត្រូវទទួលនិងវិធីសាស្រ្តគណនាការខូចខាតដោយផ្ទាល់របស់អ្នកប្តឹងទាមទារ ជាមួយនឹងការរកឃើញនិងការកំណត់របស់ GCCF។

- ការបង់ប្រាក់ស្តីទី Vs. ការបង់ប្រាក់ចុងក្រោយ— GCCF មិនពេញចិត្តយកវិធីមួយជាជាងវិធីមួយណានោះទេ។ ទីមួយ តម្រូវការភ័ស្តុតាងសម្រាប់ការបង់ប្រាក់ស្តីទីនិងការបង់ប្រាក់ចុងក្រោយគឺដូចគ្នាបេះបិត។ ទីពីរ GCCF បានថែងដដែលថាវា មិនពេញចិត្តយកវិធីមួយជាជាងវិធីមួយណានោះទេ។ ទីបីGCCF បានថែងនៅក្នុងសំបុត្រនិងរបាយការណ៍ទាំងឡាយ នៅលើវែបសាយនិងនីតិវិធីរបស់ខ្លួនដូចៗគ្នាដោយរំលឹកអ្នកប្តឹងទាមទារទាំងអស់ថាពួកគេអាចជ្រើសរើសយកការដាក់ពាក្យសុំការបង់ប្រាក់ស្តីទីឬការបង់ប្រាក់ចុងក្រោយ។ ទីបួន,នៅក្នុងការប្រតិបត្តិការឆ្នាំទីមួយ,GCCF បានបង់ប្រាក់អោយការប្តឹងទាមទារបន្ទាន់ចំនួន169,188 តាំងពីថ្ងៃទី18 ខែកុម្ភៈ ឆ្នាំ2011 ពាក្យបណ្តឹងទាមសំណងបណ្តោះអាសន្ន24,110 <u>ការទាមទារ ទាំងអស់ដែលមិនមានការបោះបង់</u>។ តាំងពីពាក់កណ្តាលខែឧសភាឆ្នាំ2011 GCCF បានទូរទាត់ប្រាក់អោយការទាមទារស្តីទីនូវទឹកប្រាក់ប្រមាណជា$2លានក្នុងមួយថ្ងៃ។ របាយការណ៍របស់GCCF នឹងបង្ហាញថា GCCF

នឹងទូរទាត់ប្រាក់អោយការទាមទារសំណងបណ្ដោះអាសន្នទាំងអស់សម្រាប់អ្នកប្ដឹងទាមទារដែលអាចបង្ហាញការបាត់បង់ជាក់ស្ដែងរបស់ពួកគេ។

* * *

តាមកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនិងក្រុមហ៊ុនBP
ដំណើរការបណ្ដឹងនឹងមានរហូតដល់ខែសីហាឆ្នាំ2013។
អ្នកដាក់ពាក្យប្ដឹងនឹងសម្រេចពេលវេលាសមស្រមសម្រាប់ដាក់ពាក្យប្ដឹង។ GCCF
នឹងបន្តធ្វើអោយប្រសើរចំពោះដំណើរដែលមាននាពេលបច្ចុប្បន្នហើយនឹងបង់ប្រាក់អោយអ្នកប្ដឹងទាមទារការបង់ប្រាក់ស្ដីទី,ការបង់ប្រាក់ភ្លាមៗឬការបង់ប្រាក់ចុងក្រោយដែលអាចបញ្ជាក់ថាការបាត់បង់របស់ពួកគេបានបណ្ដាលមកពីការលេចប្រេង។ GCCF
ត្រូវបានកំនត់អោយអនុវត្តតាមផែនការរបស់ខ្លួនដើម្បីផ្ដល់ការសងដោយភ្លាមៗនិងសប្បុរសដល់ជនរងគ្រោះនៃការលេចប្រេងដែលអាចបង្ហាញអោយឃើញថាការខូចខាតរបស់ពួកគេទាក់ទងនឹងការលេចប្រេង។ នៅពេលដែលGCCF
ចាប់ផ្ដើមដំណើរការងាររបស់ខ្លួននៅឆ្នាំទីពីរ,វានឹងបន្តធ្វើការជាមួយនឹងអ្នកប្ដឹងទាមទារនិងភាគីដែលចាប់អារម្មណ៍ដទៃទៀតក្នុងការផ្ដល់ជំនួយផ្នែកហិរញ្ញវត្ថុដល់បុគ្គលនិងអាជីវកម្មនៅក្នុងតំបន់ឆ្នេរសមុទ្រ។